**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:** ១៥៧៤ សជណ.សស

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ...
មកដល់ថ្ងៃ ... ខែ ... ឆ្នាំ ...
ម៉ោង ...

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១៤

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ វេលាម៉ោង៨និង៣០នាទី នៅអគារសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាលើៈ

១-សេចក្តីព្រាងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨។

២-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

៣-សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

៤-បញ្ហាផ្សេងៗ ។

## ១-សេចក្តីព្រាងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨

គណៈរដ្ឋមន្ត្រី បានសម្រេចឯកភាពទាំងស្រុងតាមសេចក្តីព្រាងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំស្នើឡើងមកនេះ។ ទន្ទឹមនេះ គណៈរដ្ឋមន្ត្រីបានសម្រេចឯកភាពទុកជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ និងធ្វើបច្ចុប្បន្នភាពទិន្នន័យថ្មីៗមួយចំនួនបន្ថែមទៀតតាមសំណើ ។

## ២-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥

គណៈរដ្ឋមន្ត្រីបានសម្រេចកែសម្រួលមាត្រា១៣ វាក្យខណ្ឌទី៣ ទៅជាៈ " រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារក្នុងការពិនិត្យ និងការស៊ើបអង្កេតបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័នមានសមត្ថកិច្ច ដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ " ។

ក្រៅពីការកែសម្រួលខាងលើ គណៈរដ្ឋមន្ត្រីបានសម្រេចឯកភាពតាមសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំស្នើឡើងមកនេះ។

ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥នេះ គណៈរដ្ឋមន្ត្រីបានសម្រេចប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ខិតខំពន្លឿនការអនុវត្តគម្រោងផ្លូវថ្នល់ និងធារាសាស្ត្រឲ្យបានទាន់ពេលវេលា ព្រមទាំងស្នើសុំឲ្យមានការយោគយល់ពីក្រសួង ស្ថាប័ន ដែលបានស្នើសុំថវិកា

ចំណាយ ប៉ុន្តែមិនត្រូវបានបញ្ចូល ឬក៏បញ្ចូលនូវចំនួនណាមួយមិនបានតាមសំណើទៅក្នុងគម្រោងថវិកាជាតិប្រចាំឆ្នាំ ២០១៥។ ទន្ទឹមនេះ ដើម្បីសម្រេចឲ្យបាននូវគោលដៅក្នុងការកំណត់នូវប្រាក់បៀវត្សអប្បបរមាចំនួនមួយលានរៀល សម្រាប់មន្ត្រីរាជការមួយនាក់នៅឆ្នាំ២០១៨ នោះ គណៈរដ្ឋមន្ត្រី បានសម្រេចដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម ៖

១.គ្រប់ក្រសួង ស្ថាប័នត្រូវលុបឈ្មោះខ្មោចឲ្យអស់ ទាំងខ្មោចស្លាប់ និងខ្មោចរស់។ ខ្មោចស្លាប់គឺអ្នកដែលស្លាប់ទៅហើយ ប៉ុន្តែនៅតែមានឈ្មោះក្នុងបញ្ជីបើកប្រាក់បៀវត្ស រីឯខ្មោចរស់ គឺអ្នកដែលនៅរស់មានឈ្មោះបើកប្រាក់បៀវត្ស ប៉ុន្តែមិនមកធ្វើការ ដើម្បីកាត់បន្ថយចំណាយបុគ្គលិក និងកុំឲ្យក្របខ័ណ្ឌចេះតែប៉ោងឡើង។

២.រឹតបន្តឹងការជ្រើសរើសបុគ្គលិកថ្មី ទាំងស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ទាំងការជ្រើសរើសសម្រាប់ឆ្នាំថ្មី និងការជ្រើសរើសបម្រុងទុក។ ចំពោះការជ្រើសរើសថ្មី មិនត្រូវឲ្យលើសពីចំនួនអ្នកចូលនិវត្តន៍ឡើយ។

៣.ចៀសវាងការរៀបចំបង្កើត ឬរៀបចំរចនាសម្ព័ន្ធថ្មីនៅតាមក្រសួង ស្ថាប័ន ឬនៅតាមមន្ទីរនៃរាជធានី ខេត្ត ដែលជាហេតុនាំឲ្យមានការជ្រើសរើសមន្ត្រីថ្មីសម្រាប់បម្រើការងារ។ ក៏ប៉ុន្តែ ក្នុងករណីចាំបាច់ អាចបង្កើតឬរៀបចំរចនាសម្ព័ន្ធថ្មី បានដោយគ្មាននិន្នាការជ្រើសរើសក្របខ័ណ្ឌថ្មីបន្ថែមទៀតឡើយ។

៤.ក្នុងរយៈពេលខ្លី គឺត្រូវចាប់ផ្តើមគិតគូរកម្មវិធីរិក្រឹតការបណ្តុះបណ្តាលមន្ត្រីរាជការដែលមានស្រាប់ជាខ្សែសង្វាក់នៅក្នុងក្រសួង ស្ថាប័ននីមួយៗ ដើម្បីលើកកម្ពស់ផលិតភាពការងារ និងពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការក្នុងការអនុវត្តការងាររបស់ខ្លួន។ ក្នុងន័យនេះ ក្រសួង ស្ថាប័នត្រូវប្រើមនុស្សឲ្យចំមុខងារ និងមានជំនាញច្បាស់លាស់ ហើយត្រូវរឹតបន្តឹងការងារ ចៀសវាងគិតតែពីការជ្រើសរើសមន្ត្រីថ្មី នៅពេលខ្វះមនុស្សដែលមានជំនាញធ្វើការ។

៥.ក្នុងរយៈពេលមធ្យម ត្រូវធ្វើវិភាគមុខងារនៅគ្រប់ក្រសួង ស្ថាប័នដើម្បីគោលដៅ០២យ៉ាង៖

ក-ធ្វើវិចារណកម្មការងារ និងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ដើម្បីកុំឲ្យជាន់ការងារគ្នា ឧទាហរណ៍ ដូចជាការធ្វើអធិការកិច្ចជាន់គ្នាជាដើម ដែលនាំឲ្យមានការចំណាយមិនចាំបាច់ និងជាការដាក់បន្ទុកបន្ថែមដល់ធុរជន និងប្រជាជនទូទៅ និងម្យ៉ាងទៀត ដើម្បីគិតគូរផ្ទេរមន្ត្រីពីស្ថាប័នមួយទៅស្ថាប័នមួយទៀត អាស្រ័យតាមទំហំការងារជាក់ស្តែង។

ខ-ធ្វើវិចារណកម្មនៃការប្រើប្រាស់មន្ត្រីរាជការឲ្យចំទិសដៅ ទីកន្លែង និងមុខជំនាញ និងកុំឲ្យមានមន្ត្រីរាជការមានភារកិច្ចជាន់គ្នានៅក្នុងក្រសួង ស្ថាប័ននីមួយៗ។

ការរៀបចំផែនការខាងលើ ត្រូវផ្សារភ្ជាប់ទៅនឹងកំណែទម្រង់បៀវត្ស និងការលើកទឹកចិត្តដល់មន្ត្រីរាជការ ទាំងការលើកទឹកចិត្តខាងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។ ក្រសួង ស្ថាប័ននីមួយៗ ត្រូវនាំមុខក្នុងការធ្វើការងារនេះ ដោយមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងអង្គភាពប្រឆាំងអំពើពុករលួយ ធ្វើជាស្នូលក្នុងការគាំទ្រសកម្មភាពទាំងនេះ ជាពិសេសការលុបឈ្មោះខ្មោចស្លាប់ និងខ្មោចរស់ចេញពីបញ្ជីបើកប្រាក់បៀវត្ស។

៦.ក្នុងរយៈពេលវែង រាជរដ្ឋាភិបាលនឹងកំណត់អាទិភាពនៃការធ្វើកំណែទម្រង់ប្រព័ន្ធសន្តិសុខសង្គមនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុ២០១៤-២០២០ ហើយបានសម្រេចឲ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំការងារជាមួយក្រសួង ស្ថាប័ន ដើម្បីរៀបចំ និងជំរុញអនុវត្តផែនការកំណែទម្រង់ចាំបាច់នានា រួមទាំងការសិក្សាអំពីការបញ្ចូលគ្នានូវប្រព័ន្ធផ្សេងៗ ដូចជាបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ឲ្យក្លាយជាប្រព័ន្ធតែមួយ។

៧.ផ្អាកការជ្រើសរើសបុគ្គលិកអណ្តែត និងបុគ្គលិកជាប់កិច្ចសន្យាថ្មី។ ប្រសិនបើមានការចាំបាច់ ការជ្រើសរើសនោះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យហ្មត់ចត់ ពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក.ចំពោះមុខ ត្រូវរៀបចំកិច្ចប្រតិបត្តិការស្វែងរកបុគ្គលិកអណ្តែត និងបុគ្គលិកជាប់កិច្ចសន្យាខ្មោច ដែលមានតែឈ្មោះ ប៉ុន្តែមិនមកធ្វើការ។ ប្រធានក្រសួង ស្ថាប័ននីមួយៗ ត្រូវដើរតួនាទីបោសសម្អាតបុគ្គលិកអណ្តែត និងបុគ្គលិកជាប់កិច្ចសន្យាខ្មោច ដោយមានក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយធ្វើជាស្នូលគាំទ្រកិច្ចដំណើរការនេះ។

៧.ក្នុងរយៈពេលមធ្យម ត្រូវធ្វើការវិភាគមុខងារ ដើម្បីធ្វើវិចារណកម្មប្រើប្រាស់បុគ្គលិកអណ្តែតនិង បុគ្គលិកជាប់កិច្ចសន្យា ឲ្យចំការងារពិតប្រាកដ។

៨.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវសហការជាមួយក្រសួង ស្ថាប័ន ដើម្បីពិនិត្យឡើងវិញអំពីគោលការណ៍បែងចែកប្រាក់រង្វាន់ និងគោលការណ៍ប្រើប្រាស់ប្រាក់រង្វាន់។ កិច្ចការនេះត្រូវចាប់ផ្តើមធ្វើមុនគេលើចំណូលសេវាកម្មនាំផ្លូវហោះហើរ និងនាំផ្លូវចុះចត ដែលប្រមូលដោយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ហើយបន្ទាប់មកនឹងបន្តធ្វើនៅក្រសួង ស្ថាប័នដទៃទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ឲ្យប្រកបដោយប្រសិទ្ធភាព។

៩.ក្រសួង ស្ថាប័នដែលមិនទាន់មានការទូទាត់បុរេប្រទាន ត្រូវខិតខំរកឯកសារគតិយុត្ត ដើម្បីបោះផ្សាយជម្រះបញ្ជីបុរេប្រទានឲ្យបានរួចរាល់។ នៅដំណាច់ឆ្នាំ២០១៤នេះ ប្រសិនបើក្រសួង ស្ថាប័នមានការពាក់ព័ន្ធរកឯកសារមកទូទាត់មិនបាន ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យឃើញថាមានហេតុផលត្រឹមត្រូវ ពិសេសសម្រាប់បុរេប្រទានក្នុងចន្លោះឆ្នាំ២០០៤ដល់ឆ្នាំ២០០៩ គឺក្រសួង ស្ថាប័ន អាចបោះផ្សាយអាណត្តិជម្រះបញ្ជីបុរេប្រទានតែម្តង ដោយមិនចាំបាច់មានលិខិតយុត្តាធិការឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិជម្រះបញ្ជីបុរេប្រទានដែលនៅសល់ទាំងនោះជំនួសក្រសួង ស្ថាប័នតែម្តង ក្នុងករណីដែលក្រសួង ស្ថាប័នមិនអាចបោះផ្សាយអាណត្តិដោយខ្លួនឯងបាន ដោយហេតុផលសមស្របណាមួយ ហើយក្នុងករណីចាំបាច់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចុះធ្វើអធិការកិច្ចជាមុន។

ចាប់ពីពេលនេះតទៅ រាជរដ្ឋាភិបាលនឹងរឹតបន្តឹងចំពោះការធ្វើបុរេប្រទាន និងស្នើក្រសួង ស្ថាប័ន បំភ្លេចចោលនូវការសុំធ្វើបុរេប្រទាននេះឲ្យបាន។

១០.ក្រសួង ស្ថាប័ន ដែលមានទម្លាប់ចាស់ចាយមុន សុំក្រោយ ត្រូវបញ្ឈប់សកម្មភាពនេះ ព្រោះវានៅក្រៅបរិបទថវិកា។ ប៉ុន្តែក្នុងករណីដែលចាំបាច់ត្រូវចំណាយ ក្រសួង ស្ថាប័ន ត្រូវធ្វើសំណើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល ដើម្បីបន្ថែមឥណទានសម្រាប់ចំណាយ។

១១.ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យនិងស្វែងយល់ឲ្យបានច្បាស់អំពីការចំណាយពិសេសរបស់រាជរដ្ឋាភិបាល។ ជាគោលការណ៍ ចំណាយពិសេសរបស់រាជរដ្ឋាភិបាល គឺសម្រាប់ចំណាយទៅលើគ្រោះមហន្តរាយ ករណីប្រធានសក្តិ កិច្ចការពារបូរណភាពទឹកដី ព្រះរាជពិធីបុណ្យធំៗមួយចំនួនរបស់ក្រសួងព្រះបរមរាជវាំងដែលមិនបានគ្រោងទុក និងការងារពិសេសរបស់រាជរដ្ឋាភិបាលដែលមិនមែនជាការងាររបស់ក្រសួង ស្ថាប័ន។

១២.អំពាវនាវឲ្យមានការសន្សំសំចៃថវិកា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការចំណាយ ដែលក្នុងនោះត្រូវយកចិត្តទុកដាក់ទៅលើ :

-ការបោះពុម្ព និងការទិញវត្ថុអនុស្សាវរីយ៍សម្រាប់ជូនជាកាដូដល់គណៈប្រតិភូអន្តរជាតិ។

-សន្សំសំចៃលើការប្រើប្រាស់ប្រេងឥន្ធនៈនៅតាមក្រសួង ស្ថាប័ន។

-ការចំណាយសម្រាប់បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ ចំពោះបេសកកម្មទៅក្រៅប្រទេស ត្រូវកាត់បន្ថយចំនួនសមាជិក គណៈប្រតិភូ ឬប្រសិនបើក្នុងករណីមិនចាំបាច់ អាចប្រគល់ភារកិច្ចជូនឯកអគ្គរាជទូតកម្ពុជាប្រចាំនៅបរទេសចូលរួមជំនួស។

-ការសន្សំសំចៃលើការប្រើប្រាស់បណ្តាញទូរគមនាគមន៍ និងប្រព័ន្ធអ៊ីនធើណេត នៅតាមក្រសួង ស្ថាប័ន។

-ការសន្សំសំចៃលើការប្រើប្រាស់ថាមពលអគ្គិសនីនៅតាមក្រសួង ស្ថាប័ន អង្គភាពនានា។

១៣.ចំពោះការស្នើសុំកញ្ចប់ថវិកាដោយឡែករបស់ក្រុមប្រឹក្សា ឬគណៈកម្មការអន្តរក្រសួង ស្ថាប័ន គឺត្រូវស្នើសុំនៅក្នុងឧបសម្ព័ន្ធថវិកានៃក្រសួង ស្ថាប័នពាក់ព័ន្ធណាមួយដែលបង្កើតឡើងដោយច្បាប់ពីព្រោះជាគោលការណ៍ច្បាប់ អង្គភាពទាំងឡាយណាដែលបង្កើតឡើងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ពុំមានថវិកាដោយឡែកនោះឡើយ គឺមានតែក្រសួង ស្ថាប័នដែលបង្កើតឡើងដោយច្បាប់តែប៉ុណ្ណោះ។

១៤.កន្លងទៅមានសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋខ្លះ នៅតែលើកសំណើសុំឧបត្ថម្ភធនពីរាជរដ្ឋាភិបាល ទោះបីកិច្ចដំណើរការនៃសហគ្រាសនិងគ្រឹះស្ថានរបស់ខ្លួនបានល្អហើយក៏ដោយ។ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិនិត្យឡើងវិញ ដើម្បីកាត់បន្ថយបន្ទុកថវិកាជាតិ។

**៣-សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣**

គណៈរដ្ឋមន្ត្រីបានសម្រេចឯកភាពទាំងស្រុងតាមសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំស្នើឡើងមកនេះ។

**៤-បញ្ហាផ្សេងៗ**

គណៈរដ្ឋមន្ត្រីបានសម្រេច៖

៤.១-ជម្រាបជូនសមាជិក សមាជិកានៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់អង្គភាព ដែលបានចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមប្រព័ន្ធសន្និសីទទូរទស្សន៍ អំពីការផ្តល់នូវអាវរងារបស់រាជរដ្ឋាភិបាលចំនួនជាង៤០ ០០០អាវដល់អង្គភាព កងទ័ព និងអង្គភាពនគរបាលមួយចំនួន នៅតាមតំបន់ព្រំដែនកន្លងទៅថ្មីៗនេះ និងអំពីការបន្តផ្តល់ជូនអង្គភាពកងទ័ព និងអង្គភាពនគរបាលមួយចំនួនទៀត ដែលពុំទាន់បានទទួលនាពេលកន្លងទៅ ដើម្បីទុកសម្រាប់ប្រើប្រាស់នៅក្នុងរដូវរងានាពេលខាងមុខ។ ទន្ទឹមនេះ គណៈរដ្ឋមន្ត្រីបានសម្រេចរំលឹកដាស់តឿនដល់អង្គភាពកងទ័ព និងអង្គភាពនគរបាលទាំងអស់ ដែលបានទទួលអាវរងារួចហើយ ត្រូវធ្វើការត្រួតពិនិត្យ ដើម្បីធានាឲ្យបានថា អាវរងាទាំងអស់នោះ បានទៅដល់ដៃកងទ័ព និងកងនគរបាលពិតប្រាកដ ។

៤.២-គ្មានការលើកលែងចំពោះការស្នើសុំពន្យារអាយុចូលនិវត្តន៍របស់មន្ត្រី ដែលត្រូវដល់អាយុចូលនិវត្តន៍ឡើយ ដើម្បីអនុវត្តការងារកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភានេះឲ្យទទួលបានជោគជ័យ។

៤.៣-ប្រគល់ភារកិច្ចជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលនឹងត្រូវទទួលភារកិច្ចជានាយករដ្ឋមន្ត្រីស្តីទី សូមណែនាំ និងដឹកនាំដល់កងកម្លាំងប្រដាប់អាវុធ និងរដ្ឋបាលរាជធានីភ្នំពេញឲ្យយកចិត្តទុកដាក់ក្នុងការការពារសន្តិសុខ ជានាទូវសណ្តាប់ធ្នាប់ និងសុវត្ថិភាពឲ្យបានល្អប្រសើរជូនដល់ប្រជាពលរដ្ឋ និងភ្ញៀវបរទេស ដែលបានមកចូលរួមកំសាន្តនៅរាជធានីភ្នំពេញ ក្នុងឱកាសនៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ ជាពិសេសនៅថ្ងៃទី៣ ដែលជាថ្ងៃបញ្ចប់នៃព្រះរាជពិធីនេះ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យទទួលបានលទ្ធផលជាវិជ្ជមាន។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

ចម្លងជូនៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ